ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ ២០៦
ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣
សំណុំរឿងជំនុំជម្រះលេខ ៣៣៧
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣
**សាលក្រមលេខៈ ៧៩ (គ)/៧៧៧**
ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

-បានបើកសវនាការជាសាធារណៈ នៅសាលសវនាការលេខ ក១ ។
-កាលបរិច្ឆេទបើកសវនាការ ៖ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ វេលាព្រឹក។
-កាលបរិច្ឆេទប្រកាសសាលក្រម ៖ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣ វេលាព្រឹក ។

**សមាសភាពចូលរួមសវនាការមាន៖**

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ឋានៈ ប្រធានក្រុមប្រឹក្សា
លោក [redacted] ឋានៈ ចៅក្រមប្រឹក្សា
លោក [redacted] ឋានៈ ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ឋានៈ ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ឋានៈ ក្រឡាបញ្ជី

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ២០៦ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ប្រាក់ ភេទស្រី អាយុ ៣៨ឆ្នាំ កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៨៥ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិ [redacted] ខេត្តសៀមរាប ទីលំនៅមុនពេលឃាត់ខ្លួននៅហាងម៉ាស្សា អង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី៣ មុខរបរម្ចាស់ហាងម៉ាស្សា អង្គរសុវណ្ណ ប្តីឈ្មោះ [redacted] ពិសិដ្ឋ (លែងលះ) មានកូនចំនួន ៤ នាក់ ឪពុកឈ្មោះ [redacted] សារឿន (រស់) ម្តាយឈ្មោះ [redacted] លឹម (រស់) ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១២៧ ឃខ/ឈ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ (អវត្តមាន) ។

២.ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ភេទស្រី អាយុ ៤៦ឆ្នាំ កើតថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ទីកន្លែងកំណើតនៅភូ [redacted] ខេត្តព្រៃវែង ទីលំនៅមុនពេលឃាត់ខ្លួននៅហាងម៉ាស្សា អង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កម្រិតវប្បធម៌ថ្នាក់ទី៣ មុខរបរនារីម៉ាស្សា ប្តីឈ្មោះ [redacted] ហុង (ស្លាប់) មានកូនចំនួន ២ នាក់ ឪពុកឈ្មោះ [redacted] ថន(ស្លាប់) ម្តាយឈ្មោះ [redacted] ឡាន (រស់) ទោសពីមុនគ្មាន ។ (ក្នុងឃុំ)



Scanned with CamScanner

ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១២៨ យខ/ឈ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិ ។

ជាប់ចោទពីបទ សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែធ្នូ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៣.ឈ្មោះ [redacted] ហិប ហៅ កែវ ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅភូ[redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅសណ្ឋាគារហ្គោលថោន(ភូមិស្ទឹងថ្មី) កម្រិតវប្បធម៌ថ្នាក់ទី២ មុខរបរបុគ្គលិកអចលនទ្រព្យ មេម៉ាយ ឪពុកឈ្មោះ [redacted] សារឿន (រស់) ម្ដាយឈ្មោះ [redacted] លឹម (រស់) ទោសពីមុន គ្មាន ។ (គេចខ្លួន)

ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៨៣ ចខស/ឈ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ ។

ជាប់ចោទពីបទ នាំយកអនីតិជនជាអាទិ៍ ចេញដោយមិនស្របច្បាប់ ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

**ជនរងគ្រោះ**

ឈ្មោះ [redacted] ស្រីលក្ខណ៍ ភេទស្រី កើតថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៤ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ [redacted] ខេត្តព្រះវិហារ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងភ្លោះ ឃុំពង្រ ស្រុកជីក្រែង ខេត្តសៀមរាប នៅលីវ ឪពុកឈ្មោះ [redacted]រី (រស់) ម្ដាយឈ្មោះ [redacted]ជៀស (រស់) ។

ឈ្មោះ [redacted] ចាន់កលិកា ភេទស្រី កើតថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៣ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ខេត្តព្រះវិហារ ទីលំនៅបច្ចុប្បន្ននៅភូមិកំពេញ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នៅលីវ ឪពុកឈ្មោះ [redacted]ពុទ្ធវិច្ឆិកា (រស់) ម្ដាយឈ្មោះ [redacted] ស្រីធឿន (រស់) ។

**ដើមបណ្តឹងរដ្ឋប្បវេណី**

ឈ្មោះ [redacted] ជៀស ភេទស្រី អាយុ ៤៣ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិក្រាច ឃុំសំប្រោច ស្រុកស្ទោង ខេត្តកំពង់ធំ ទីលំនៅបច្ចុប្បន្ននៅភូមិត្រពាំងភ្លោះ ឃុំពង្រលើ ស្រុកជីក្រែង ខេត្តសៀមរាប ប្តីឈ្មោះ [redacted]រី មានកូន ៥នាក់ ឪពុកឈ្មោះ [redacted]ជឿន (រស់) ម្តាយឈ្មោះ ជា (ស្លាប់) ។

ឈ្មោះ [redacted] ស្រីធឿន កើតថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៨៧ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិឈើទាលភ្លោះ ឃុំប្រាំបីមុំ ស្រុកទ្រាំង ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ននៅភូមិកំពេញ ឃុំយាង ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ប្តីឈ្មោះ[redacted] យឿន មានកូនចំនួន ៤នាក់ ឪពុកឈ្មោះ [redacted] បុល (ស្លាប់) ម្តាយឈ្មោះ [redacted] សៀវ (រស់) ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី (អវត្តមាន) ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី (អវត្តមាន) ។

លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី (អវត្តមាន) ។



Scanned with CamScanner

## អង្គហេតុកើតឡើងមានដូចតទៅ៖

កាលពីអំឡុងខែធ្នូ ឆ្នាំ២០២២ ឈ្មោះ [redacted] ប្រាក់ ជាថៅកែហាងម៉ាស្សាយីហោ អង្គរសុវណ្ណ ដែលមានទីតាំងស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប បានលួងលោមឈ្មោះ [redacted] ចាន់កលិកា កើតនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៧ ឱ្យមកធ្វើការនៅកន្លែងម៉ាស្សារបស់ខ្លួន ដោយកុហកថា ឱ្យមកធ្វើការរត់តុក្នុងក្រុងសៀមរាប និងផ្ដល់ប្រាក់ខែឲ្យ ១០០(មួយរយ)ដុល្លារអាមេរិក ប៉ុន្តែជាក់ស្តែងគឺមកបម្រើការនៅកន្លែងម៉ាស្សាយីហោ អង្គរសុវណ្ណ ។ រំលងបានមួយថ្ងៃឈ្មោះ [redacted] ប្រាក់ បានបង្ខំឱ្យឈ្មោះ [redacted] ចាន់កលិកា ភេទស្រី អាយុ ១៦ឆ្នាំ រួមភេទជាមួយភ្ញៀវប្រុសម្នាក់ដោយឈ្មោះ [redacted] ប្រាក់ ជាអ្នកទទួលប្រាក់ពីភ្ញៀវ ហើយបានប្រគល់ប្រាក់ទៅឱ្យជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា ចំនួន ២០.០០០ (ពីរម៉ឺន) រៀល ។ ឈ្មោះ [redacted] ប្រាក់ បានបង្ខំឱ្យឈ្មោះ [redacted] ចាន់កលិកា រួមភេទជាមួយភ្ញៀវនៅថ្ងៃបន្តបន្ទាប់ បានប្រហែល ១០(ដប់)ថ្ងៃ ទើបជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា បានសុំឈប់ធ្វើការ ប៉ុន្តែឈ្មោះ [redacted] ប្រាក់ មិនបើកប្រាក់ខែឱ្យ និងបានតម្រូវឱ្យជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា បង់ប្រាក់ចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) រៀល ។ ក្រៅពីជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា នៅក្នុងហាងម៉ាស្សាយីហោ អង្គរសុវណ្ណ ក៏មានជនរងគ្រោះម្នាក់ទៀតឈ្មោះ [redacted] ស្រីលក្ខណ៍ អាយុ ១៧ឆ្នាំ ដែលត្រូវបានឈ្មោះ [redacted] ហ៊ិប ហៅ កែវ ភេទស្រី អាយុ ៣៣ឆ្នាំ បានកុហកលួងលោម ថាឱ្យមកធ្វើការរត់តុក្នុងហាងគុយទាវ ក្នុងក្រុងសៀមរាប ប៉ុន្តែជាក់ស្តែង គឺមកបម្រើការនៅកន្លែងម៉ាស្សាយីហោ អង្គរសុវណ្ណ ។ ឈ្មោះ [redacted] ហ៊ិប ហៅ កែវ បានហាមជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ មិនឱ្យប្រាប់ម្តាយពីព្រោះឈ្មោះ [redacted] ហ៊ិប ហៅ កែវ ខ្លាចម្តាយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ មិនឱ្យមក ។

បានឃើញ របាយការណ៍សំយោគលេខ ០៨៣/២៣ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ផ្នែកការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងការងារយេនឌ័រ នៃការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៦៧ អយជ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៩៤០ ពស.ព្រស/ឈ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជ្រះលេខ ៣៤៦ ពស.ព្រជ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

១.ជនជាប់ចោទឈ្មោះ [redacted] ម៉ាលី ហៅ ចែកធំ បានឆ្លើយថា ខ្លួនជាបុគ្គលិកម៉ាស្សាផង និងជាអ្នកមើលការខុសត្រូវជំនួសឲ្យម្ចាស់ហាងម៉ាស្សាអង្គរសុវណ្ណផង ។ នៅក្នុងហាងម៉ាស្សាមានបុគ្គលិកទាំងអស់ចំនួន ៣ នាក់ មានឈ្មោះ [redacted] ស្រីលក្ខណ៍ ឈ្មោះ [redacted] ចាន់កលិកា រួមទាំងរូបខ្លួន ។ ហាងម៉ាស្សានេះចាប់បើកនៅឆ្នាំ២០១៩ រហូតដល់ថ្ងៃសមត្ថកិច្ចចាប់ឃាត់ខ្លួន ។ ខ្លួនចូលធ្វើការងារនៅក្នុងហាងនេះឆ្នាំ២០២០ ពេលនោះមានតែរូបខ្លួន និងថៅកែហាងប៉ុណ្ណោះ ។ ក្រោយមកក៏មានជនរងគ្រោះទាំងពីរនាក់ចូលធ្វើការជាងមួយខែក៏មានរឿងត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ ជនរងគ្រោះទាំងពីរនាក់ជាអ្នកសុំថៅកែហៅចូលធ្វើការងារខ្លួនឯង ។



Scanned with CamScanner

ហាងម៉ាស្សានេះពុំមានបម្រើសេវាកម្មផ្លូវភេទទេ ។ ហាងម៉ាស្សានេះមានស្រាប់ ខ្លួនពុំបានរៀបចំអ្វីបន្ថែមទៀតទេ ហាងនេះមានចំនួន ៤ បន្ទប់ បាំងវាំងននពុំមានបន្ទប់ទឹកក្នុងនោះទេ ។ អ្នកធ្វើការនៅទីនោះកាន់ម្នាក់មួយបន្ទប់ ។ ខ្លួនកាន់មួយបន្ទប់ដែរ ហើយរស់នៅក្នុងហាងម៉ាស្សានោះតែម្តង ។ ជនរងគ្រោះចូលធ្វើការគ្រប់អាយុទាំងអស់ ដោយមានបង្ហាញអត្តសញ្ញាណប័ណ្ណ ខ្លួនក៏បានឃើញអត្តសញ្ញាណប័ណ្ណនោះដែរ ។ ហាងម៉ាស្សានោះមានសេវាកោសជប់ម៉ាស្សាធម្មតា ពុំមានម៉ាស្សាប្រេងឡើយ ហើយក៏ពុំមានអ្នករួមភេទនៅក្នុងហាងម៉ាស្សានេះដែរ ។ តម្លៃម៉ាស្សាមួយម៉ោង ១៥.០០០៛ (មួយម៉ឺនប្រាំពាន់រៀល) ក្នុងនោះថៅកែដកយកចំនួន ១០.០០០៛ (មួយម៉ឺនរៀល) អ្នកម៉ាស្សាបានចំនួន ៥.០០០៛ (ប្រាំពាន់រៀល)។ ខ្លួនពុំចេះអក្សរទេ បានជាដឹងថា ជនរងគ្រោះគ្រប់អាយុព្រោះថៅកែប្រាប់ខ្លួន និងបង្ហាញអត្តសញ្ញាណប័ណ្ណ ដែលនៅក្នុងទូរស័ព្ទរបស់ថៅកែឲ្យខ្លួនមើល ។ ស្រោមអនាម័យដែលសមត្ថកិច្ចដកហូតជារបស់ខ្លួន គឺខ្លួនទុកប្រើប្រាស់ជាមួយសង្សារខ្លួនម្តងម្គារ ។ ការរួមភេទជាមួយសង្សារខ្លះរួមភេទក្នុងហាង ខ្លះទៀតនៅក្រៅ ។ ខ្លួនពុំដែលរួមភេទជាមួយអ្នកផ្សេងក្រៅពីសង្សារទេ ។ ជនរងគ្រោះខ្លួនពុំដែលបង្ខំឲ្យរួមភេទជាមួយភ្ញៀវ ។ ខ្លួនពុំដែលហាមឃាត់ជនរងគ្រោះមិនឲ្យចេញក្រៅទេ គេចង់ទៅណាជាសិទ្ធិរបស់គាត់ ដោយគាត់គ្រាន់តែប្រាប់ខ្លួន ។ ខ្លួនពុំដែលទទួលប្រាក់ពីជនរងគ្រោះលើពីតម្លៃម៉ាស្សាឡើយ ។

២.ជនរងគ្រោះឈ្មោះ [redacted] ប្រាក់ បានឆ្លើយថា ហាងម៉ាស្សានេះខ្លួនបានសេងយកពីគេ ដោយសារមានគេអ្នកណែនាំឲ្យខ្លួនសេង ព្រោះគេថា ចំណេញ ។ ពេលខ្លួនសេងហាងនោះមានបុគ្គលិកធ្វើការចំនួន ៥ នាក់ ក្រោយសេងហាងបាន ៥ ថ្ងៃ បុគ្គលិកទាំងនោះឈប់ធ្វើការទាំងអស់គ្នា ។ ពេលខ្លួនសេងហាងនេះ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ពុំទាន់ចូលធ្វើការងារជាមួយខ្លួនទេ ។ ពេលឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ចូលធ្វើការមានបុគ្គលិកម្នាក់ ។ ម៉ាស្សាក្នុងមួយម៉ោងតម្លៃ ១៥.០០០៛ (មួយម៉ឺនប្រាំពាន់រៀល) ដោយខ្លួនដកយក ១០.០០០៛ (មួយម៉ឺនរៀល) ឲ្យថ្លៃអ្នកម៉ាស្សាចំនួន ៥.០០០៛ (ប្រាំពាន់រៀល) ។ ហាងរបស់ខ្លួនបើកពីម៉ោង ៩ព្រឹក ឬ ម៉ោង ១០ព្រឹក និងបិតវិញនៅម៉ោង ១យប់ ។ ពេលខ្លួនសេងហាងពីគេ គឺចំសម័យកូវីដ១៩ត្រូវអាជ្ញាធរបិទ ទោះបីអាជ្ញារឲ្យបើកវិញក៏មិនមានភ្ញៀវចូលឡើយ ។ ខ្លួនពុំដែលបង្ខំឲ្យជនរងគ្រោះរួមភេទឡើយ បើបុគ្គលិកចង់រួមភេទជាសិទ្ធិរបស់គាត់ តែមិនអនុញ្ញាតឲ្យរួមភេទនៅក្នុងហាងឡើយ ។ ករណីដែលបុគ្គលិកធ្វើការរបស់ខ្លួនត្រូវរ៉ូវគ្នាជាមួយភ្ញៀវចង់ចេញទៅក្រៅ គឺខ្លួនយកមួយម៉ោង ១៥.០០០៛ (មួយម៉ឺនប្រាំពាន់រៀល) ។ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ជាអ្នកមើកការខុសត្រូវជំនួសខ្លួន ពេលខ្លួនមិននៅក្នុងហាង ហើយគាត់ក៏ជាបុគ្គលិកម៉ាស្សាដែរ ។ ស្រោមអនាម័យដែលសមត្ថកិច្ចដកហូតនេះ គឺខាងអង្គការចែកទុកឲ្យដោយចែកគ្រប់ហាងម៉ាស្សាទាំងអស់ ។ ក្មេងស្រីទាំងពីរនាក់នេះ គឺមកសុំខ្លួនធ្វើការទាំងអស់ ខ្លួនពុំបានហៅមកធ្វើការឡើយ ។ ឈ្មោះ [redacted] ស្រីលក្ខណ៍ ពេលសុំខ្លួនចូលធ្វើការ គាត់បានបញ្ជាក់ប្រាប់អាយុ ១៩ឆ្នាំ ខ្លួនក៏សួររកអត្តសញ្ញាណប័ណ្ណ តែគាត់ប្រាប់ថា អត្តសញ្ញាណប័ណ្ណឆេះអស់ ។ ពេលគាត់សុំចូលធ្វើការនេះក៏ប្រាប់ខ្លួនថា ធ្លាប់មានសង្សារ និងធ្លាប់យកកូនចេញម្តង ។ ឈ្មោះ [redacted] ចាន់កលិកា សុំខ្លួនចូលធ្វើការប្រាប់ខ្លួនថា អាយុ ២០ឆ្នាំ និងបានបង្ហាញអត្តសញ្ញាណប័ណ្ណឲ្យខ្លួនមើលថែមទៀត ។ ខ្លួនពិតជាបានយកថ្លៃទឹក ថ្លៃភ្លើងបន្ថែមពីជនរងគ្រោះទាំងពីរនាក់នេះមែន ដោយសារគាត់ទាំងពីរនាក់រស់នៅទីនោះ និងប្រើប្រាស់ភ្លើងហ្វ៊ើត ចោលហ្វេត ។ ពេលសមត្ថកិច្ចចុះបង្ក្រាប គឺបានដកហូតស្រោមអនាម័យមិនទាន់ប្រើទាំងអស់មិនមានស្រោមអនាម័យណាប្រើឡើយ ។ ចម្លើយពីមុនមកខ្លួនសុំបដិសេធចោលទាំងអស់ ។



Scanned with CamScanner

៣.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជៀស បានឆ្លើយថា ខ្លួនជាអ្នកស៊ីឈ្នួលធ្វើចំការឲ្យម្ដាយរបស់ឈ្មោះ [redacted] ប្រាក់ ។ គាត់ជាអ្នកហៅកូនខ្លួនឲ្យមកធ្វើការ ដោយមិនបានប្រាប់ថា ធ្វើការងារអ្វីនោះទេ ។ កូនខ្លួនពុំដឹងថា កើតថ្ងៃខែឆ្នាំណាទេ តែខ្លួនដឹងថា កើតឆ្នាំរកា ។ ក្នុងរឿងនេះ ខ្លួនពុំប្ដឹងទាមទារសំណងអ្វីពីជនជាប់ចោទឡើយ និងសុំដកពាក្យបណ្ដឹងចាប់ពីពេលនេះតទៅ ។ កូនខ្លួនធ្លាប់មានប្ដីម្ដងឈ្មោះ [redacted] តែបានលែងលះគ្នាហើយ ។ ឥឡូវនេះកូនខ្លួនមានសំបុត្រកំណើតហើយ ដោយខាងអង្គការជាអ្នកនាំទៅធ្វើ ដោយកូនខ្លួនប្ដូរឈ្មោះខ្លួនឯង ។

៤.ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស្រីធឿន បានឆ្លើយថា ខ្លួនជាម្ដាយរបស់ឈ្មោះ [redacted] ចាន់ កលិកា បច្ចុប្បន្នខ្លួនរស់នៅខេត្តព្រះវិហារ ពុំធ្លាប់រស់នៅខេត្តសៀមរាបឡើយ ។ ដោយសារជីវភាពក្រីក្រកូនសុំមកធ្វើការងាររោចចក្រនៅភ្នំពេញ ។ ពេលកូនចេញមកធ្វើការងារនៅឆ្នាំ២០២១ ។ កូនធ្វើការងាររោចចក្របានរយៈពេល ៣ខែ កូនក៏សុំមកធ្វើការជាអ្នកលក់អចលនទ្រព្យនៅខេត្តសៀមរាប ។ កូនខ្លួនមាន អាយុ ១៦ឆ្នាំ តែពេលចេញធ្វើការងារខ្លួនបានធ្វើអត្តសញ្ញាណប័ណ្ណឲ្យកូនអាយុ ១៨ឆ្នាំ ។ ពេលគាត់ឈប់ធ្វើការងារកន្លែងលក់អចលនទ្រព្យគាត់ប្រាប់ថា មកធ្វើការងារនៅកន្លែងរត់តុ ។ ក្រោយមកខ្លួនបានយកកូនរបស់ខ្លួនពីខេត្តព្រះវិហារមកព្យាបាលនៅមន្ទីរពេទ្យគន្ធបុប្ផា កូនរបស់ខ្លួនមកសួរសុខទុកតែគាត់មិនបាន ប្រាប់ពីកន្លែងធ្វើការងាររបស់គាត់ទេ ។

៥.ជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត បានឆ្លើយថា ឈ្មោះ [redacted] ហិប ហៅ កែវ ជាអ្នកទៅហៅខ្លួនពីផ្ទះនៅខេត្តព្រះវិហារ ដោយនិយាយថា ឲ្យខ្លួនជាអ្នករត់តុគុយទាវនៅខេត្តសៀមរាប ។ តែជាក់ស្ដែងឈ្មោះ [redacted] ហិប ហៅ កែវ បាននាំខ្លួនមកធ្វើការនៅហាងម៉ាស្សាអង្គរសុវត្ថិទៅវិញ ។ នៅពេលឈ្មោះ [redacted] ហិប ហៅ កែវ ទៅហៅខ្លួនមកធ្វើការ គឺខ្លួនបានសុំម្ដាយខ្លួនតែម្ដាយខ្លួនបដិសេធមិនឲ្យមក។ តែខ្លួនលួចមក ដោយពេលនោះឈ្មោះ [redacted] ហិប ហៅ កែវ បានឲ្យខ្លួនខ្ចីប្រាក់ ដើម្បីធ្វើដំណើរមក ហើយពេលខ្លួនមានប្រាក់នឹងសងវិញ ។ ពេលខ្លួនជិះរថយន្តមកដល់ខេត្តសៀមរាប ឈ្មោះ [redacted] ហិប ហៅ កែវ បាននាំខ្លួនទៅផ្ទះរបស់ឈ្មោះ [redacted] ប្រាក់ សម្រាក់នៅទីនោះមួយព្រឹក លុះល្ងាចឈ្មោះ [redacted] ហិប ហៅ កែវ នាំខ្លួនមកហាងម៉ាស្សាតែម្ដង ។ ពេលនោះខ្លួនបានប្រកែកដែលតែឈ្មោះ [redacted] ហិប ហៅ កែវ ប្រាប់ថា ឲ្យធ្វើការនៅទីនោះសិន ។ ថ្ងៃធ្វើការដំបូងខ្លួនទទួលភ្ញៀវប្រុសម៉ាស្សាម្នាក់ ថ្ងៃបន្ទាប់ខ្លួនទទួលភ្ញៀវប្រុសម្នាក់ទៀត ដោយភ្ញៀវនោះសួររកសេវារួមភេទ ខ្លួនឲ្យភ្ញៀវនោះទៅសួរឈ្មោះ [redacted] ប្រាក់ ។ ក្រោយមកឈ្មោះ [redacted] ប្រាក់ បានមកប្រាប់ខ្លួនថា ថ្លៃសេវារួមភេទទទួលពីភ្ញៀវចំនួន ២៥$(ម្ភៃប្រាំដុល្លារអាមេរិក) ទៅ ៣០$ (សាមសិបដុល្លារអាមេរិក) ពេលនោះខ្លួនបានប្រកែកដែលតែគាត់បានប្រាប់ខ្លួនថា បើមិនរួមភេទជាមួយភ្ញៀវបានប្រាក់ណាបង់ថ្លៃបន្ទប់ផ្ទះល ទឹក ភ្លើង ។ ខ្លួនក៏បានរួមភេទជាមួយភ្ញៀវតែម្ដង កម្រៃពីការរួមភេទជាមួយភ្ញៀវខ្លួនយកទៅឲ្យឈ្មោះ [redacted] ប្រាក់ ឬ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ហើយគេឲ្យថ្លៃឈ្នួលខ្លួនពីការរួម ភេទចំនួន ១០.០០០៛ (មួយម៉ឺនរៀល) ចំពោះថ្លៃម៉ោងម៉ាស្សាក្នុងមួយម៉ោងទទួលបានចំនួន ៥.០០០៛ (ប៉ាំពាន់រៀល) ។ តាំងពីខ្លួនចូលធ្វើការមកទទួលភ្ញៀវម៉ាស្សាជាងដប់នាក់ ហើយរួមភេទជាមួយភ្ញៀវប្រហែលប្រាំបីនាក់ ។ ខ្លួនធ្លាប់មានសង្សារនៅខេត្តព្រះវិហារ មិនធ្លាប់មានប្ដី ឬយកកូនចេញនោះទេ ។

៦.ជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា បានឆ្លើយថា ខ្លួនស្គាល់កូនរបស់ឈ្មោះ [redacted] ប្រាក់ ។ ក្រោយមកខ្លួនបានសុំទៅសម្រាក់នៅផ្ទះគាត់ ។ ពេលខ្លួនសម្រាក់នៅផ្ទះរបស់ឈ្មោះ [redacted] ប្រាក់ គាត់ថា ឲ្យខ្លួនទៅធ្វើការជាអ្នករត់តុគុយទាវខ្លួនក៏ព្រម តែឈ្មោះ [redacted] ប្រាក់ បែរជានាំខ្លួនទៅធ្វើការជាអ្នកម៉ាស្សាទៅវិញ

ដោយគាត់ប្រាប់ថា ធ្វើការងារនេះបានប្រាក់លឿនជាង ។ ចូលធ្វើការងារដំបូងពុំទាន់មានភ្ញៀវសុំរួមភេទទេ នៅថ្ងៃបន្តបន្ទាប់ទៀត គឺមានភ្ញៀវសួររកសេវារួមភេទ ។ តាំងពីខ្លួនធ្វើការជាអ្នកម៉ាស្សា គឺធ្លាប់រួមភេទជាមួយភ្ញៀវបានចំនួនពីរនាក់ ប្រាក់ថ្លៃរួមភេទ និងម៉ាស្សាឲ្យទៅឈ្មោះ [redacted] ប្រាក់ ថ្លៃម៉ោងធ្វើការ និងរួមភេទទទួលបានដូចឈ្មោះ [redacted] ស្រីលក្ខណ៍ ។ ខ្លួនធ្វើការងារនៅហាងម៉ាស្សាជាងកន្លះខែ ចេញក្រៅតែទៅផ្សារប៉ុណ្ណោះ កន្លែងផ្សេងទៀតពុំធ្លាប់ទៅ ។ មិនបានរឿងធ្វើការងារម៉ាស្សាប្រាប់អ្នកផ្ទះនោះទេ ។ ខ្លួនចេញធ្វើការងារប្រើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ កើតថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៧ ។ ពេលខ្លួនចូលធ្វើការងារនៅមិនបានបង្ហាញអត្តសញ្ញាណប័ណ្ណឲ្យឈ្មោះ [redacted] ប្រាក់ មើលនោះទេ ។ ពេលឈ្មោះ [redacted] ប្រាក់ ប្រាប់ឲ្យខ្លួនរួមភេទបាននិយាយថា បើមិនរួមភេទបានប្រាក់ពីណា បង់ថ្លៃបន្ទប់ជួល ទឹក ភ្លើង ។

## សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យដើមបណ្ដឹងរដ្ឋប្បវេណី

លោកមេធាវី [redacted] បានធ្វើសេចក្ដីសន្និដ្ឋានការពារថា ក្រោយពីបញ្ចប់ការសួរដេញដោលលើកទីពីរនេះ ខ្ញុំបាទសុំធ្វើការសន្និដ្ឋានដូចតទៅ៖

ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ជាប់ចោទពីបទ សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ជនជាប់ចោទឈ្មោះ [redacted] ហិប ហៅ កែវ ជាប់ចោទពីបទ នាំយកអនីតិជនជាអាទិ៍ ចេញដោយមិនស្របច្បាប់ តាមបញ្ញត្តិមាត្រា ៩ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ឃើញថា ជនជាប់ចោទទាំងបីនាក់ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់មែន ដោយក្នុងនោះឈ្មោះ [redacted] ប្រាក់ ជាម្ចាស់ហាងសុវណ្ណអង្គរ ចំណែកឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ជាអ្នកមើលការខុសត្រូវបន្តពីឈ្មោះ [redacted] ប្រាក់ ។ ក្រោយពីជនរងគ្រោះរួមភេទជាមួយភ្ញៀវរួច ឬម៉ាស្សាឲ្យភ្ញៀវរួច គឺជនរងគ្រោះយកប្រាក់ថ្លៃសេវារួមភេទឲ្យទៅឈ្មោះ [redacted] ប្រាក់ ឬឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ។ អំពើនេះ ឃើញថា ជាការទាញយកផលចំណេញ និងផលប្រយោជន៍ពីការរួមភេទរបស់ជនរងគ្រោះ ។ ចំពោះអាយុជនរងគ្រោះឃើញថាជាអនីតិជន ចំពោះការកែប្រែអាយុវាពុំពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌឡើយ ។ ដូចនេះមានធាតុផ្សំគ្រប់គ្រាន់ពីបទ សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ចំពោះជនជាប់ចោទឈ្មោះ [redacted] ហិប ហៅ កែវ ពិតជាបានធ្វើសកម្មភាពនាំជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត ពីខេត្តព្រះវិហារមកខេត្តសៀមរាប ដើម្បីធ្វើការងារម៉ាស្សា និងរួមភេទ ។ ដូចនេះ មានធាតុផ្សំគ្រប់គ្រាន់ពីបទ នាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ តាមបញ្ញត្តិមាត្រា ៩ នៃច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ចំពោះខាងអង្គការបានធ្វើនីតិវិធីបណ្ដឹងតាមការប្ដឹងរាយការណ៍ពីដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះ ហើយចំពោះការដកពាក្យបណ្ដឹងរបស់ជនរងគ្រោះ និងដើមបណ្ដឹងរដ្ឋប្បវេណីនេះជាឆន្ទៈរបស់ពួកគាត់ៗ។ ដូចនេះ ខ្ញុំបាទស្នើសុំឲ្យតុលាការសម្រេចតាមច្បាប់ ។

## សេចក្ដីសន្និដ្ឋានផ្ដាច់សុំរបស់តំណាងអយ្យការ

ក្រោយពីបានបញ្ចប់ការសួរដេញដោល ឃើញថា ពិតជាមានអង្គហេតុ និងបទចោទប្រកាន់ ដូចដីកាសន្និដ្ឋានស្ថាពរពិតមែន ។ ពាក់ព័ន្ធអាយុជនរងគ្រោះតំណាងអយ្យការទុកសិទ្ធិជូនតុលាការពិនិត្យលើភស្តុតាងផ្សេងៗសម្រេចតាមច្បាប់ ។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានដូចតទៅ:

### ១-អំពីអង្គហេតុ

(១)អំឡុងខែធ្នូ ឆ្នាំ២០២២ ឈ្មោះ [redacted] ប្រាក់ ជាថៅកែហាងម៉ាស្សាយីហោអង្គសុវណ្ណ មានទីតាំងនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប បានលួងលោមឈ្មោះ [redacted] តាន់គុលិកា កើតថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៧ មកធ្វើការកន្លែងម៉ាស្សារបស់ខ្លួនដោយប្រាប់ថាមកធ្វើការរត់តុក្នុងក្រុងសៀមរាបនិងផ្តល់ប្រាក់ខែ១០០ដុល្លារ ។ រំលងមួយថ្ងៃឈ្មោះ [redacted] ប្រាក់ បានបង្ខំឱ្យឈ្មោះ [redacted] តាន់កលិកា រួមភេទ ជាមួយភ្ញៀវម្នាក់ ដោយឈ្មោះ [redacted] ប្រាក់ ទទួលប្រាក់ពីភ្ញៀវហើយឱ្យ [redacted] តាន់គុលិកា ចំនួន២ម៉ឺនរៀល។ ឈ្មោះ [redacted] ប្រាក់ បានបង្ខំឱ្យឈ្មោះ [redacted] តាន់កលិកា រួមភេទ ជាមួយ ភ្ញៀវនៅថ្ងៃបន្តបន្ទាប់ប្រហែល១០ដង ទើបជនរងគ្រោះឈ្មោះ [redacted] តាន់កលិកា សុំឈប់ ធ្វើការ ប៉ុន្តែឈ្មោះ [redacted] ប្រាក់ មិនបើកប្រាក់ខែឱ្យ និងបានតម្រូវឱ្យជនរងគ្រោះឈ្មោះ [redacted] តាន់កលិកា បង់ប្រាក់ចំនួន ៧០.០០០ (ប្រាំពីរម៉ឺន) រៀល ។ ក្រៅពីជនរងគ្រោះ ឈ្មោះ [redacted] តាន់កលិកា នៅក្នុង ហាងម៉ាស្សាយីហោ អង្គសុវណ្ណ ក៏មានជនរងគ្រោះម្នាក់ទៀតឈ្មោះ [redacted] ស្រីលក្ខណ៍ អាយុ១៧ឆ្នាំ ដែលត្រូវ បានឈ្មោះ [redacted] ហ៊ិប ហៅ កែវ ភេទស្រី អាយុ ៣៣ឆ្នាំ បានកុហកលួងលោម ថាឱ្យមកធ្វើការរត់តុក្នុងហាងគុយទាវក្នុងក្រុងសៀមរាប ប៉ុន្តែជាក់ស្តែង គឺមកបម្រើការនៅកន្លែងម៉ាស្សា យីហោ អង្គសុវណ្ណ ។ ឈ្មោះ [redacted] ហ៊ិប ហៅ កែវ បានហាមជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ មិនឱ្យប្រាប់ម្តាយ ពីព្រោះឈ្មោះ [redacted] ហ៊ិប ហៅ កែវ ខ្លាចម្តាយ របស់ជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ មិនឱ្យមក ។ ផ្អែកតាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ ហាងម៉ាស្សាយីហោ អង្គសុវណ្ណ ឈ្មោះ [redacted] ប្រាក់ គឺជាម្ចាស់ទីតាំង ហើយមានបុគ្គលិកម្នាក់ ទៀតឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ដែលបានជួយមើលការខុសត្រូវលើរូបខ្លួននិងឈ្មោះ [redacted] តាន់កលិកា នៅពេលដែលម្ចាស់ទីតាំងមិននៅ ។ នៅក្នុងអំឡុងពេលស្នាក់នៅហាងម៉ាស្សាខាងលើឈ្មោះ [redacted] ប្រាក់ បានបង្ខំឱ្យឈ្មោះ [redacted] ស្រីលក្ខណ៍ រួមភេទជាមួយភ្ញៀវក្នុង ១ (មួយ) ម៉ោង តម្លៃពី១៥(ដប់ប្រាំ)ដុល្លារអាមេរិក ទៅ ៣០(សាមសិប) ដុល្លារអាមេរិក ដោយឈ្មោះ [redacted] ប្រាក់ ប្រគល់ប្រាក់ឱ្យខ្លួនចំនួន ២០.០០០(ពីរម៉ឺន) រៀល រីឯប្រាក់ដែលសល់ គឺឈ្មោះ [redacted] ប្រាក់ យកទាំងអស់ ។

### ២-ចំណាត់ការនីតិវិធីតុលាការ

(២)អង្គហេតុខាងលើនេះ ត្រូវបានតំណាងអយ្យការសម្រេចធ្វើការចោទប្រកាន់លើឈ្មោះ [redacted] ប្រាក់ ឈ្មោះ [redacted] ម៉ាលី ពីបទ "សញ្ញារកម្មទាក់ទងពេស្យាចារកុមារ" តាមមាត្រា២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គសុវណ្ណស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែធ្នូ ឆ្នាំ២០២២ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២១៨ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ និងដីកាសន្និដ្ឋាន ស្ថាពរលេខ ២៦៧ អយជ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២៣។

(៣) ក្រោយពីបានស៊ើបសួរចប់សព្វគ្រប់ ចៅក្រមស៊ើបសួរបានបញ្ជូនឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ព្រមទាំងសំណុំរឿងព្រហ្មទណ្ឌលេខ ២០៦ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ទៅជំនុំជម្រះតាមដីកាសម្រេចលេខ ១៩៤០ ពស.ព្រស/ឈ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ។

៧០
៨

(៤)នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ សាលាដំបូងខេត្តសៀមរាប បានលើកសំណុំរឿងព្រហ្មទណ្ឌ លេខ ២០៦ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ខាងលើមកធ្វើការជំនុំជម្រះ និងប្រកាសសាលក្រមលេខ ០១៧/១៤ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២៣ ដោយសម្រេចចាត់រៀប *ដើម្បីស៊ើបសួរ ថ្ងៃ ខែ ឆ្នាំ កំណើត* របស់ឈ្មោះ [redacted] ចាន់កលិកា និងឈ្មោះ[redacted]ចិត្ត ឬ[redacted]ស្រីលក្ខណ៍ ។

**៣-សេចក្តីថ្លែងការណ៍ដោះសារ និងមធ្យោបាយការពារខ្លួន**
**អំពីធាតុសង្សានុម័តះ**

១-តាមការពិនិត្យភស្តុតាង ជាឯកសារនៅក្នុងសំណុំរឿងឃើញថា៖ ឯកសារសំបុត្រកំណើតរបស់ឈ្មោះ [redacted] ចាន់កលិកា លេខ៦២ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៤ ចេញដោយសាលាសង្កាត់កំបូល ដែលមន្ត្រីនគរបាលយុត្តិធម៌បានដាក់បញ្ជូនជាភស្តុតាង មានថ្ងៃខែឆ្នាំកំណើត 0៩ មិថុនា ២00៧ ជាភស្តុតាងដែលមាន មានវិមតិសង្ស័យមិនអាចយកជាមូលដ្ឋានក្នុងការផ្តន្ទាទោសលើឈ្មោះ[redacted] ប្រាក់ និងឈ្មោះ[redacted]ម៉ាលី ដោយស្ថានទម្ងន់ទោសបាននោះទេ ព្រោះតាមការបញ្ជាក់របស់មន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានខណ្ឌកំបូល បានបញ្ជាក់ថាគល់បញ្ជីនៃសំបុត្រកំណើតលេខ៦២ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ពុំមានរក្សាទុកនៅរដ្ឋបាលខណ្ឌទេ។ ផ្ទុយទៅវិញ តាមឯកសារយោងមុនពេលធ្វើអត្តសញ្ញាណប័ណ្ណរបស់ឈ្មោះ[redacted]ចាន់កលិកា ដែលផ្តល់ដោយ អធិការដ្ឋានស្រុកជាំក្សានខេត្តព្រះវិហារ ដូចជា ៖ ១/លិខិតសំបុត្រ កំណើតថតចម្លង ចុះថ្ងៃទី0៩ ខែមិថុនា ឆ្នាំ២00៣របស់ឈ្មោះ [redacted] ចាន់កលិកា ២/សាលាកប័ត្រព័ត៌មាន ថតចម្លងចុះថ្ងៃទី0២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] ចាន់កលិកា ៣/សាលាកប័ត្រផ្តល់ថ្មីស្នាមមេដៃ [redacted] ចាន់កលិកា ថតចម្លងចុះថ្ងៃទី0២ ខែវិច្ឆិកា ឆ្នាំ២០២២ សុទ្ធតែអាចបញ្ជាក់ថា [redacted] ចាន់កលិកា គឺជានីតិជនដែលកើតនាថ្ងៃទី0៩ ខែមិថុនា ឆ្នាំ២00៣ គប្បីឱ្យតុលាការពិចារណាបដិសេធចោលនូវភស្តុតាងរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

២-ពុំមានភស្តុតាងជាក់លាក់ ដែលអាចបញ្ជាក់ពីអង្គហេតុដែលឈ្មោះ [redacted] រឿន និងឈ្មោះ[redacted] ម៉ាលី បង្ខិតបង្ខំឱ្យឈ្មោះ ណុប ចាន់កលិកា និងឈ្មោះ [redacted]ស្រីលក្ខណ៍ រួមភេទជាមួយភ្ញៀវ និងបានដកយកប្រាក់ដែលជាហិរញ្ញវត្ថុពីអំពើរួមភេទនោះទេ ក្រៅតែពីចម្លើយចោទប្រកាន់របស់ឈ្មោះ [redacted] ចាន់កលិកា និងឈ្មោះ [redacted]ស្រីលក្ខណ៍ ។

៣-ចម្លើយរបស់សាក្សីឈ្មោះ [redacted] ចាន់ធឿន និងឈ្មោះ [redacted] ជៀស គឺជាភស្តុតាងជាចម្លើយដែលបានដឹងលឺតៗគ្នា និងមានលក្ខណៈប្រយោល មិនបានឃើញ មិនបានឮដោយភ្នែកនិងត្រចៀកឡើយ ដែលគ្មានតម្លៃជាព័ត៌មានដែលតុលាការមិនគួរ គប្បីយកមកពិចារណាក្នុងការសម្រេចផ្តន្ទាទោស បទឧក្រិដ្ឋលើឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted]ម៉ាលី ឡើយ ។

៤-តាមការឆ្លើយបញ្ជាក់របស់មន្ត្រីនគរបាលប៉ុស្តិ៍នគរបាលឃុំសំព្រោច ស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានបញ្ជាក់ក្នុងកំណត់ហេតុស្តីពីការស្តាប់ចម្លើយ(កិច្ចស៊ើបសួរបន្ថែម) ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តសៀមរាប បានបញ្ជាក់យ៉ាងច្បាស់ថា ឈ្មោះ [illegible]ចិត្ត កើតថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៤ ដែលមានចុះក្នុងតារាងសម្រង់មនុស្សក្នុងគ្រួសារ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ និងឈ្មោះ[redacted] ស្រីលក្ខណ៍ កើតនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ ដែលបានចុះនៅក្នុងសៀវភៅស្នាក់នៅ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ គឺជាមនុស្សតែម្នាក់ និងបានបញ្ជាក់បន្ថែមទៀតថា អត្តសញ្ញាណរបស់មនុស្សដែលបានចុះក្នុងតារាងសម្រង់មនុស្សក្នុងបន្ទុកគ្រួសារ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ ដែលឈ្មោះ



Scanned with CamScanner

[redacted]ចិត្ត ឬឈ្មោះ[redacted]ស្រីលក្ខណ៍ កើតថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៤ គឺពិតជាត្រឹមត្រូវ និងធ្វើឡើងតាមនីតិវិធីស្របច្បាប់ ។ ប៉ុន្តែផ្ទុយទៅវិញការដែលកើតមានឡើងនូវសៀវភៅស្នាក់នៅចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដាក់ថាឈ្មោះ[redacted]ស្រីលក្ខណ៍ ឬឈ្មោះ[redacted]ចិត្ត កើតនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ ដោយសារមានស្ត្រីចំនួនពីរនាក់កាន់តែលិខិតសំណើររបស់មេភូមិត្រាចជុំ និងបានអះអាងថា ពួកគេជាបុគ្គលិកអង្គការមកជួយស្នើសុំធ្វើសំបុត្រកំណើត និងសៀវភៅគ្រួសារឲ្យឈ្មោះ[redacted]ចិត្ត ឬឈ្មោះ[redacted]ស្រីលក្ខណ៍ ដោយពួកគេអះអាងប្រាប់ថាឈ្មោះ[redacted]ចិត្ត ឬឈ្មោះ[redacted]ស្រីលក្ខណ៍ ពុំមានឯកសារអ្វីផ្សេងទេ ក្រៅតែពីសំបុត្រកំណើតដែលទើបធ្វើជំណាលនឹងគ្នាដែរ ។ មិនតែប៉ុណ្ណោះស្ត្រីទាំងពីរនាក់ដែរ អះអាងថាជាបុគ្គលិកអង្គការនោះ បានប្រាប់បន្ថែមទៀត ថាមកជួយធ្វើឯកសារឲ្យឈ្មោះ[redacted] ចិត្ត ឬ[redacted]ស្រីលក្ខណ៍ ដោយសារក្មេងនោះកំពុងស្នាក់នៅជាមួយឪពុកចុង និងពុំមានឯកសារបញ្ជាក់អត្តសញ្ញាណអ្វីផ្សេងទេ ។

៥-តាមពាក្យសុំដកពាក្យបណ្ដឹង ចុះថ្ងៃទី ១១ ខែតុលា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ជាសបានបញ្ជាក់ថាស្នើសុំដកពាក្យបណ្ដឹងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ២០៦ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

៦-តាមពាក្យសុំ ដកពាក្យបណ្ដឹងចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ របស់ឈ្មោះ [redacted] ចាន់ធឿន បានបញ្ជាក់ថាស្នើសុំដកពាក្យបណ្ដឹងក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ២០៦ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងខេត្តសៀមរាប។

**អំពីធាតុអន្លោម៍ឥះ**

១-ឈ្មោះ [redacted] ធឿន បានសារភាពថា ខ្លួនពិតជាម្ចាស់ ហាងម៉ាស្សាយីហោ អង្គរ សុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប មែន ប៉ុន្តែបានបដិសេដថា ខ្លួនមិនបានបង្ខិតបង្ខំឱ្យឈ្មោះ [redacted] ចាន់កលិកា រួមភេទជាមួយភ្ញៀវទេ។

២-ឈ្មោះ [redacted] មាលី បានឆ្លើយសារភាពថា ខ្លួនពិតជាបានធ្វើការក្នុងហាងម៉ាស្សាកោសជប់យីហោអង្គរសុវណ្ណ ដែលមានថៅកែឈ្មោះ [redacted] ប្រាក់ មែន ប៉ុន្តែបានបដិសេដថាខ្លួនមិនបានប្រព្រឹត្តដូចការចោទប្រកាន់នោះទេ។

៣-ភស្តុតាងដាក់បន្ទុក និងចម្លើយដាក់បន្ទុករបស់សាក្សីនិងជនរងគ្រោះ មកលើឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី គឺជាភស្តុតាងដែលជាលក្ខណៈជាសម្ដីរបស់បុគ្គលដែលមានភាពថ្លាំងថ្នាក់គ្នា មិនគប្បីឱ្យតុលាការយកជាមូលដ្ឋានដាក់លាក់ក្នុងការផ្ដន្ទាទោសដែលមានលក្ខណៈជាបទឧក្រិដ្ឋ ។

៤-បុគ្គលិកលក្ខណៈរបស់សាក្សី[redacted] ស្រីលក្ខណ៍ និងរបស់ឈ្មោះ [redacted] ចាន់កលិកា គឺជាបុគ្គលដែលមានទម្លាប់លាក់បាំង ដូចជាការកែប្រែព័ត៌មាននៃអត្តសញ្ញាណ សាវតាជាតិពិតប្រាកដរបស់ខ្លួន ទាំងឈ្មោះដូចជាពីឈ្មោះ[redacted]ចិត្ត មក[redacted]ស្រីលក្ខណ៍ ព្រមទាំងថ្ងៃខែឆ្នាំកំណើត និងឈ្មោះ[redacted]ចាន់កលិកា ធ្វើសំបុត្រកំណើតចំនួន ២ ផ្សេងគ្នាផងនោះ ដូចមានបញ្ជាក់ក្នុងរបាយការណ៍ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣ របស់អង្គការសមាគមន៍អន្តរជាតិនៃកម្ពុជា ដែលនេះ គប្បីតុលាការថ្លឹងថ្លែងនិងពិចារណាវ មិនយកចម្លើយនេះជាមូលដ្ឋានដាក់បន្ទុកមកលើឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ដែលជាប់ចោទពីបទឧក្រិដ្ឋ ។



Scanned with CamScanner

អំពីធាតុនីត្យានុកូល៖

១-មាត្រា ២៨ "សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ" នៃច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទ ចែងថា៖ សញ្ញារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបុគ្គលធ្វើពេស្យាចារនោះជាអនីតិជន ។

២-មាត្រា៣៨នៃរដ្ឋធម្មនុញ្ញបានចែងថា៖

វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

៣-មាត្រា១១០ "អំណាចធ្វើមូលវិចារណ៍របស់ចៅក្រម" នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ៖ តាមគោលការណ៍កំណត់ហេតុ មានតម្លៃគ្រាន់តែជាព័ត៌មានប៉ុណ្ណោះ ។ ប៉ុន្តែកំណត់ហេតុរបស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវទុកជាបន្ទាល់"ឯកសារដើម" មានន័យថា ត្រូវទុកជាឯកសារដែលគួរជឿរហូតដល់មានភស្តុតាងផ្ទុយ ។ ភស្តុតាងផ្ទុយអាចជូនមកចៅក្រមបានដោយសេរីតាមគ្រប់មធ្យោបាយត្រឹមត្រូវតាមច្បាប់ ។ ចៅក្រមធ្វើមូលវិចារណ៍ដោយសេរី លើកំណត់ហេតុដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង។

៤-ផ្អែកតាមការពិនិត្យឯកសារ ភស្តុតាងផ្សេងៗដែលមាននៅក្នុងសំណុំរឿង ឃើញថាលក្ខណៈជាសារធាតុនៃអង្គហេតុក្នុងសំណុំរឿងនេះ គឺគ្មានវត្តមានអនីតិជនក្នុងអង្គហេតុ នៃការចោទប្រកាន់ឡើយ ថែមទាំងមានភស្តុតាងដោះបន្ទុក ជាឯកសារដែលផ្តល់ជូនដោយអធិការដ្ឋាននគរបាលស្រុកជាំក្សាន និងការឆ្លើយបញ្ជាក់របស់មន្ត្រីនគរបាលប៉ុស្តិ៍រដ្ឋបាលឃុំសំព្រោច ស្រុកស្ទោង ខេត្តកំពង់ធំ ដូចមាន បញ្ជាក់ ក្នុងកំណត់ហេតុស្តីពីការស្តាប់ចម្លើយ(កិច្ចស៊ើបសួរបន្ថែម) ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប ដែលគប្បីឱ្យតុលាការពិចារណា បដិសេធនូវភស្តុតាងរបស់មន្ត្រីនគរបាលយុត្តិធម៌ តាមស្មារតីនៃមាត្រា ១១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លើសពីនេះការចោទប្រកាន់សំអាងតែលើចម្លើយរបស់សាក្សីឈ្មោះ [redacted] ស្រីល័ក្ខណ៍ និងរបស់ឈ្មោះ [redacted] ចាន់កលិកា យកជាមូលដ្ឋានក្នុងការដាក់បន្ទុក លើឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ទាំងដែលភស្តុតាង ជាចម្លើយរបស់បុគ្គល ដែលមិនមានលក្ខណៈក្នុងការគួរឱ្យជឿបាន រហូតដល់ថ្នាក់ត្រូវផ្តន្ទាទោសដាក់ ពន្ធនាគារបុគ្គលណាម្នាក់ពីបទឧក្រិដ្ឋ ដែលផ្ទុយនឹងស្មារតី នៃគោលការណ៍វិមតិសង្ស័យត្រូវបាន ជាប្រយោជន៍ដល់ជនជាប់ចោទ ។

៤. សេចក្តីសន្និដ្ឋាន និងសំណូមពរ

(៥)តាមរយៈការពិភាក្សាដេញដោល និងការពិនិត្យភស្តុតាងនៅក្នុងសំណុំរឿង ក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ស្នើសុំ **លោកប្រធានក្រុមប្រឹក្សា** មេត្តាពិនិត្យពិចារណាសម្រេចចេញសាលក្រមចុងក្រោយដោយសម្រេចប្រកាសឱ្យឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី រួចផុតពីបទចោទ សញ្ញារកម្មទាក់ទងពេស្យាចារកុមារ ដែលមានចែងកំណត់ក្នុងបញ្ញត្តមាត្រា២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពី ជួញដូរមនុស្ស និងអំពើអាជីវកម្មផ្លូវភេទដោយក្តីអនុគ្រោះ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ខ្លួនឯកភាពតាមសេចក្តីសន្និដ្ឋានរបស់សហសភាគាខាងលើ ។

**សំដីចុងក្រោយរបស់ជនជាប់ចោទ**

-ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី បានសំណូមពរមកតុលាការថា ស្នើសុំឱ្យខ្លួនមានសេរីភាព ។

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់ចម្លើយ និងអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើភស្តុតាងឯកសារផ្សេងៗក្នុងសំណុំរឿង

-ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១.ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ និងឈ្មោះ [redacted] ហិប ហៅ កែវ ត្រូវបានតំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ចោទប្រកាន់ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ២០៦ ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ ដោយឈ្មោះ [redacted] ប្រាក់ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ជាប់ចោទពីបទ សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងឈ្មោះ [redacted] ហិប ហៅ កែវ ជាប់ចោទពីបទ នាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ តាមបញ្ញត្តិមាត្រា ៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ បន្ទាប់មកជនជាប់ចោទខាងលើត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តសៀមរាប សម្រេចចេញដីកាបញ្ជូនមកជំនុំជម្រះពីបទល្មើសខាងលើដដែល តាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៩៤០ ពស.ព្រស/ឈ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣ ។ ដូចនេះ នាំឲ្យតុលាការមានសមត្ថកិច្ចក្នុងការជំនុំជម្រះសំណុំរឿងខាងលើនេះ ស្របតាមបញ្ញត្តិមាត្រា ២៨៩ និងមាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២.យោងតាមបញ្ញត្តិមាត្រា ៩ កថាខណ្ឌទី ១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា ជនណានាំយកអនីតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬ នៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ចេញដោយមិនស្របច្បាប់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥(ប្រាំ) ឆ្នាំ ។

៣.យោងតាមបញ្ញត្តិមាត្រា ២៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ចែងថា សញ្ចារកម្ម ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះជាអនីតិជន ។

៤.ផ្អែកតាមការសួរដេញដោលជនជាប់ចោទនាពេលសវនាការ ឃើញថា ជនជាប់ចោទទាំងពីរនាក់មានឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ បានឆ្លើយបដិសេធបទចោទប្រកាន់ និងអង្គហេតុចោទប្រកាន់របស់តំណាងអយ្យការ ។ ចម្លើយបដិសេធរបស់ជនជាប់ចោទទាំងពីរនេះ មិនអាចឲ្យតុលាការជឿបានឡើយ បើតាមការសួរដេញដោលលើជនរងគ្រោះនាពេលសវនាការឈ្មោះ [redacted] ស្រីល័ក្ខណ៍ និងឈ្មោះ [redacted] ចាន់កលិកា បានឆ្លើយថា ខ្លួនពិតជាត្រូវបានជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ បង្ខំឲ្យរួមភេទជាមួយភ្ញៀវដែលមកម៉ាស្សានៅក្នុងហាងយីហោអង្គរសុវណ្ណ ។ មួយវិញទៀត បើតាមកំណត់ហេតុផែកឆេរ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និង



Scanned with CamScanner

ការពារអនីតិជន រកឃើញ សៀវភៅបញ្ជីគិតប្រាក់ស្ត្រីជាបុគ្គលិកម៉ាស្សាចំនួន ១ ក្បាលដែល បានចាប់យកពីបន្ទប់ឈ្មោះ [redacted] ប្រាក់ និងចាប់យកស្រោមអនាម័យមិនទាន់ប្រើប្រាស់ចំនួន ៨ ។ ដូចនេះ តុលាការជឿជាក់ថា ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ពិតជាបានប្រព្រឹត្តបទល្មើសសញ្ចារកម្មប្រាកដមែន ។

៥.ការចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ពីបទ សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងឈ្មោះ [redacted] ហិប ហៅ កែវ ជាប់ចោទពីបទ នាំយកអនីតិជនជាអាទិ៍ ចេញដោយមិនស្របច្បាប់ តាមបញ្ញត្តិមាត្រា ៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដោយផ្អែកលើជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា និងឈ្មោះ [redacted] ស្រីលក្ខណ៍ ជាអនីតិជន ឃើញថា ពុំមានភាពត្រឹមត្រូវឡើយ ដោយហេតុថា:

ក.តាមការពិនិត្យកស្តុតាងជាឯកសារលើជនរងគ្រោះឈ្មោះ [redacted] ចាន់កលិការ មានសំបុត្រកំណើតលេខ ៦២ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ សៀវភៅកំណើតលេខ ០២/២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋាន សង្កាត់កំបូល គឺជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា កើតថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៣ ហើយជនរងគ្រោះបានប្រើប្រាស់សំបុត្រកំណើតនេះ ដើម្បីយកទៅធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដោយបានបំពេញសលាកប័ត្រព័ត៌មានសម្រាប់សុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២១ រហូតដល់មន្ត្រីមានសមត្ថកិច្ចចេញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ២២០២៣៩៥៥៥ សុពលភាព ចុះថ្ងៃទី៤ ខែមករា ឆ្នាំ២០២២ ដល់ថ្ងៃទី៤ ខែមករា ឆ្នាំ២០៣២ ដែលជនរងគ្រោះប្រើប្រាស់បំពេញការងាររហូតមក ។ ដូចនេះ បើគិតត្រឹមថ្ងៃប្រព្រឹត្តបទល្មើសនៅខែធ្នូ ឆ្នាំ២០២២ ឃើញថា ជនរងគ្រោះឈ្មោះ [redacted] ចាន់កលិកា ជានីតិជន ។

ខ.តាមការពិនិត្យកស្តុតាងជាឯកសារលើជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត មានពាក្យសុំផ្លាស់ប្តូរទីលំនៅ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ មានស្នាមមេដៃអ្នកដាក់ពាក្យសុំឈ្មោះ [redacted] រី លិខិតអនុញ្ញាតផ្លាស់ប្តូរទីលំនៅ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤ របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលសំព្រោចតារាងសម្រង់មនុស្សក្នុងបន្ទុកគ្រួសារ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២២ មានស្នាមមេដៃឈ្មោះ [redacted] រី ហត្ថលេខាអនុសេនីយ៍ឯក [redacted] សារុន លិខិតបញ្ជាក់ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ របស់លោកមេភូមិអូរ និងមេឃុំខ្នារលិខិតបញ្ជាក់លេខ ៣៤២/២០២៣ របស់នាយប៉ុស្តិ៍ឃុំសំព្រោច និងកំណត់ហេតុស្តីពីការស្តាប់ចម្លើយមន្ត្រីនគរបាលឃុំសំព្រោច ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២៣ ឃើញថា ជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត កើតថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៤ ។ ដូចនេះ បើគិតត្រឹមថ្ងៃប្រព្រឹត្តបទល្មើស នៅខែធ្នូ ឆ្នាំ២០២២ ឃើញថា ជនរងគ្រោះ ឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត ជានីតិជន ។

៦.ផ្អែកតាមសំអាងហេតុខាងលើ ឃើញថា ការចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ពីបទ សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងឈ្មោះ [redacted] ហិប ហៅ កែវ ពីបទ នាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ តាមបញ្ញត្តិមាត្រា ៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពុំមានលក្ខណៈត្រឹមត្រូវ ឬ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់តាមច្បាប់ឡើយ ដោយអំពើ



Scanned with CamScanner

ប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ មានជាតុផ្សំបទល្មើស តាមបញ្ញត្តិមាត្រា ២៥ កថាខណ្ឌទី១ ចំណុច ១ និងចំណុច ៤ មាត្រា ២៧ កថាខណ្ឌទី១ ចំណុច ៣ និង ចំណុច ៥ និងឈ្មោះ [redacted] ហ៊ប ហៅ កែវ តាមបញ្ញត្តិមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។ ដូចនេះ គប្បីតុលាការកែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ប្រាក់ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ពីបទ សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ តាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទៅបទ ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម តាមបញ្ញត្តិមាត្រា ២៥ និងមាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងឈ្មោះ [redacted] ហ៊ប ហៅ កែវ ពីបទ នាំយកអនីតិជនជាអាថ៌ចេញដោយមិនស្របច្បាប់ តាមមាត្រា ៩ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ទៅបទ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ តាមបញ្ញត្តិមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

៧.ឈ្មោះ [redacted] ចាន់កលិការ បានសារភាពថា ខ្លួនគឺជាអ្នកកត់ត្រាបញ្ជីចំណូលក្នុងការធ្វើម៉ាស្សា និងការធ្វើពេស្យាចារក្នុងហាងម៉ាស្សានេះ។ ឈ្មោះ [redacted] ចាន់កលិការ បានអះអាងថា ខ្លួនគឺជាស្រីលក់ខ្លួនផងដែរ នៅពេលណាមានភ្ញៀវពេញចិត្ត និងនិយាយត្រូវរ៉ូវគ្នាពីតម្លៃរួមភេទដោយគ្មានការបង្ខិតបង្ខំពីម្ចាស់ហាងឈ្មោះ [redacted] ប្រាក់ នោះទេ។

៨.ម្ចាស់ហាងម៉ាស្សាឈ្មោះ [redacted] ប្រាក់ បានទទួលភាគរយពីតម្លៃម៉ាស្សា និងតម្លៃធ្វើពេស្យាចារដែលមានកត់ត្រាក្នុងបញ្ជីចំណូលប្រចាំថ្ងៃ។

៩.សៀវភៅបញ្ជីចំណូលប្រចាំថ្ងៃការម៉ាស្សា និងការធ្វើពេស្យាចារនេះ គឺជាភស្តុតាងដាក់បន្ទុកក្នុងអំពើល្មើសច្បាប់នេះ។

១០.ឈ្មោះ [redacted] ប្រាក់ ជាម្ចាស់ហាងម៉ាស្សា ពុំដែលបង្ខិតបង្ខំឱ្យនារីម៉ាស្សាធ្វើអំពើពេស្យាចារនោះទេ គឺជាការស្ម័គ្រចិត្តរបស់នារីម៉ាស្សា ដែលបានត្រូវរ៉ូវព្រមព្រៀងគ្នាជាមួយភ្ញៀវតែប៉ុណ្ណោះ។

១១.ម្ចាស់ហាងម៉ាស្សាស្ថិតក្នុងស្ថានភាពផ្តល់កន្លែងឱ្យគេប្រព្រឹត្តអំពើពេស្យាចារ និងបានទទួលកម្រៃពីអំពើពេស្យាចារនេះផងដែរ។

១២.ឈ្មោះ [redacted] ប្រាក់ ជាស្ត្រីមេម៉ាយមានកូនតូច ៤ នាក់ ស្ថិតក្នុងបន្ទុក ដែលតម្រូវឱ្យគាត់ទទួលខុសត្រូវចិញ្ចឹមបីបាច់ថែរក្សាដល់កូនតូចៗនោះដែរ។

១៣.ជនជាប់ចោទឈ្មោះ [redacted] ហ៊ប ហៅ កែវ ត្រូវបានកោះហៅចូលរួមសវនាការតាមដីកាកោះហៅជនជាប់ចោទឲ្យចូលមកកាន់សវនាការ បុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២៣ ត្រឹមត្រូវតាមច្បាប់ តែជនជាប់ចោទរូបនេះ អវត្តមានគ្មានមូលហេតុ ។ ប៉ុន្តែតាមការសួរដេញដោលលើជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត ថា ខ្លួនរស់នៅខេត្តព្រះវិហារជាកម្មករដកដំឡូង ។ ក្រោយមកឈ្មោះ [redacted] ហ៊ប ហៅ កែវ បានទាក់ទងខ្លួនឲ្យមកធ្វើការងារនៅខេត្តសៀមរាបជាអ្នករត់តុ ដោយឈ្មោះ [redacted] ហ៊ប ហៅ កែវ ចេញថ្លៃឆ្នូក ចេញសោហ៊ុយថ្លៃធ្វើដំណើរឲ្យខ្លួនជាមុនសិន នៅពេលធ្វើការបានប្រាក់នឹងសងគាត់វិញ ។ ពេលធ្វើដំណើរដល់ខេត្តសៀមរាប ឈ្មោះ [redacted] ហ៊ប ហៅ កែវ បាននាំខ្លួនទៅផ្ទះរបស់ឈ្មោះ [redacted] ប្រាក់ សម្រាក់នៅទីនោះមួយព្រឹក លុះល្ងាចឡើងឈ្មោះ [redacted] ហ៊ប ហៅ កែវ បាននាំខ្លួនទៅធ្វើការងារនៅកន្លែងម៉ាស្សានៅហាង



Scanned with CamScanner

យីហោ អង្គរសុវណ្ណ ហេតុទាល់តែដល់ថ្ងៃសមត្ថកិច្ចចុះបង្ក្រាបតែម្តង ។ ផ្អែកតាមចម្លើយរបស់ជនរងគ្រោះ ឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត និងសំអាងហេតុចំណុច ៥.ខ ខាងលើឃើញថា អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ហ៊ិប ហៅ កែវ មានធាតុផ្សំបទល្មើសគ្រប់គ្រាន់ពីបទ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

១៤.ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ និងឈ្មោះ [redacted] ហ៊ិប ហៅ កែវ ជានីតិជន ដែលមានការយល់ដឹងគ្រប់គ្រាន់ចំពោះសកម្មភាពប្រព្រឹត្តរបស់ខ្លួន ហេតុនេះជនជាប់ចោទត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ។

១៥.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប្រាក់ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ និងឈ្មោះ [redacted] ហ៊ិប ហៅ កែវ ប្រព្រឹត្តឡើងក្នុងចេតនាទុច្ចរិត ជាមនុស្សមានស្មារតីល្អ និងមានការយល់ដឹងច្បាស់លាស់ពីអំពើ និងបច្ច័យដែលកើតមានឡើងនៃអំពើរបស់ខ្លួន តែជនជាប់ចោទនៅតែប្រព្រឹត្តបទល្មើស ដែលធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសាធារណៈ សន្តិសុខសង្គម កិត្តិយស សេចក្តីថ្លៃថ្នូរ សុខភាព របស់អ្នកដទៃ ប្រពៃណីទំនៀមទម្លាប់ ពិសេសខុសនឹងច្បាប់ជាធរមាន ។

១៦.មានពិរុទ្ធភាព និងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ៖

ក.ឈ្មោះ [redacted] ប្រាក់ ភេទស្រី កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៨៥ និងឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ភេទស្រី កើតថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧ ពីបទ សញ្ញារកម្មមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុង ខែធ្នូ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

ខ.ឈ្មោះ [redacted] ហ៊ិប ហៅ កែវ ភេទស្រី អាយុ ៣៣ឆ្នាំ ពីបទ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

១៧.ការប្រកាសអំពីទោស៖ ស្ថានភាពនៃបទល្មើសកើតឡើងក្នុងវិបត្តិនៃជំងឺកូវីដ១៩ ហើយជនជាប់ចោទជួលផ្ទះរបស់គេប្រកបរបររកស៊ីត្រូវការប្រាក់ ដើម្បីដោះស្រាយថ្លៃឈ្នួលផ្ទះ ថ្លៃទឹក ភ្លើង និងជីវភាពផ្សេងទៀត ។ ជនជាប់ចោទជាស្ត្រីមេម៉ាយ បន្ទុកគ្រួសារត្រូវធ្លាក់លើជនជាប់ចោទទាំងស្រុង ដែលស្ថានភាពទាំងនេះនាំឲ្យជនជាប់ចោទប្រព្រឹត្តបទល្មើស ។ នាពេលសវនាការដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះអះអាងអំពីការដកពាក្យបណ្តឹង និងមានការដកពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៣ ដោយមិនប្តឹងទាមទារសំណងខូចខាត ឬជំងឺចិត្តពីជនជាប់ចោទឡើយ ។ ផ្អែកតាមស្ថានភាពទាំងនេះ គប្បីតុលាការផ្តល់ស្ថានសម្រាលទោសលើជនជាប់ចោទឈ្មោះ [redacted] ប្រាក់ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ និងឈ្មោះ [redacted] ហ៊ិប ហៅ កែវ តាមបញ្ញត្តិមាត្រា ៩៤ កថាខណ្ឌទី២ មាត្រា ១០៧ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

១៨.ដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ ដកពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៣ ដោយមិនប្តឹងទាមទារសំណងខូចខាត ឬជំងឺចិត្តពីជនជាប់ចោទឡើយ ។ ដូចនេះ តុលាការមិនលើកយកការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណីមកពិចារណាឡើយ ។

## ហេតុដូច្នេះ សម្រេច

**១.ផ្តន្ទាទោស ៖**

១.១.ឈ្មោះ [redacted] ប្រាក់ ភេទស្រី កើតថ្ងៃទី១០ ខែមករា ឆ្នាំ១៩៨៥ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសពន្ធនាគារចំនួន ៨ (ប្រាំបី) ខែ ទោសដែលនៅសល់ត្រូវអនុវត្តទោសព្យួរជម្ងតា ។

១.២.ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ ភេទស្រី កើតថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៧ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសពន្ធនាគារចំនួន ៨ (ប្រាំបី) ខែ ទោសដែលនៅសល់ត្រូវអនុវត្តទោសព្យួរជម្ងតា ។

ពីបទ សញ្ញារកម្មមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែធ្នូ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៥ និងមាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

១.៣.ឈ្មោះ [redacted] ហ៊ិប ហៅ កែវ ភេទស្រី អាយុ ៣៣ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ៥ (ប្រាំ) ឆ្នាំ តែទោសនេះត្រូវអនុវត្តទោសព្យួរជម្ងតា ។

ពីបទ ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាអង្គរសុវណ្ណ ស្ថិតនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប កាលពីអំឡុងខែវិច្ឆិកា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១០ នៃច្បាប់ស្តីពីការបង្ក្រាប អំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប្រាក់ ឈ្មោះ [redacted] ម៉ាលី ហៅ ចែធំ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហ៊ិប ហៅ កែវ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជៀស និងឈ្មោះ [redacted] ស្រីធឿន ចំពោះមុខជនរងគ្រោះឈ្មោះ [redacted] ស្រីលក្ខណ៍ ឬហៅ [redacted] ចិត្ត ឈ្មោះ [redacted] ចាន់កលិកា ។

**ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។**

**ហត្ថលេខា និងត្រា** **ហត្ថលេខា** **ហត្ថលេខា** **ហត្ថលេខា និងត្រា**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧
សៀមរាប ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**
**ប្រធានក្រុមប្រឹក្សា**

[redacted]



Scanned with CamScanner